# ព្រះរាជក្រម

នស/រកម/០២១៦/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤

# ជំពូកទី ១

# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

## ផ្នែកទី ១

## កិច្ចប្រតិបត្តិការទូទៅ

### មាត្រា ១.-

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ។ ការអនុវត្តនេះ សម្រេចបានលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោម :

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = (I.១ + II.១) | ១៣ ៦៦៥ ៦២៧,០ | ១៥ ២៧០ ៩៤០,៨ | ១១១,៧% | +១ ៦០៥ ៣១៣,៨ |
| សរុបចំណាយ = (I.២ + II.២) | ១៣ ៥៩៥ ៦២៧,០ | ១៤ ០៦៧ ៩៣២,០ | ១០៣,៥% | +៤៧២ ៣០៥,០ |
| អតិរេកថវិការវាងចំណូលនិងចំណាយ | +៧០ ០០០,០ | +១ ២០៣ ០០៨,៨ | | |
| I. កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | ១០ ២០៥ ៦២៧,០ | ១១ ០៣០ ៤៦០,៩ | ១០៨,១% | +៨២៤ ៨៣៣,៩ |
| • ចំណូលចរន្ត | ៩ ៧១២ ៦២៧,០ | ១០ ៨២៩ ៦៩៦,៦ | ១១១,៥% | +១ ១១៧ ០៦៩,៦ |
| • ចំណូលមូលធនក្នុងប្រទេស | ២៣៣ ០០០,០ | ១៨៣ ៩៩៦,១ | ៧៩,០% | -៤៩ ០០៣,៩ |
| • ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៦០ ០០០,០ | ១៦ ៧៦៨,២ | ៦,៤% | -២៤៣ ២៣១,៨ |
| I.២.ចំណាយថវិកា | ១០ ១៣៥ ៦២៧,០ | ៩ ៨២៧ ៤៥២,១ | ៩៧,០% | -៣០៨ ១៧៤,៩ |
| • ចំណាយចរន្ត | ៨ ២៦៨ ៧០៣,០ | ៨ ២០៤ ៤៤១,៧ | ៩៩,២% | -៦៤ ២៦១,៣ |
| • ចំណាយមូលធន | ១ ៨៦៦ ៩២៤,០ | ១ ៦២៣ ០១០,៤ | ៨៦,៩% | -២៤៣ ៩១៣,៦ |
| II.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% | +៧៨០ ៤៧៩,៩ |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៤៦០ ០០០,០ | ៤ ២៤០ ៤៧៩,៩ | ១២២,៦% | +៧៨០ ៤៧៩,៩ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២.-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានបង្ហាញលម្អិតតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤: ចំពោះចំណូលត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង "ក" និងចំពោះចំណាយត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង "ខ២" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

## ផ្នែកទី ២
## កិច្ចប្រតិបត្តិការចំណូល-ចំណាយអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា ៣.-**

ការប្រមូលចំណូលជាគុណប្រយោជន៍នៃថវិកាថ្នាក់ជាតិពីពន្ធ អាករ វិភាគទាន ផលទុន និងចំណូលនានា ព្រមទាំងឧបត្ថម្ភធនវិនិយោគ អំណោយ មូលនិធិបដិភាគ និងធនធាន ដែលបានមកពីការខ្ចី ដូចមានចែងក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ :

- ច្បាប់ហិរញ្ញវត្ថុ.............................................. ១០ ២០៥ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន......................... ១១ ០៣០ ៤៦០,៩ លានរៀល

ដូច្នេះ ចំណូលអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន......៨២៤ ៨៣៣,៩ លានរៀល ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ :

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ...............................................៩ ៧១២ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន..........................១០ ៨២៩ ៦៩៦,៦ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.........................១ ១១៧ ០៦៩,៦ លានរៀល ។

២. ចំណូលមូលធន
- ច្បាប់ហិរញ្ញវត្ថុ...............................................៤៩៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន..................................២០០ ៧៦៤,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២៩២ ២៣៥,៧ លានរៀល ។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២៣៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ១៨៣ ៩៩៦,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ៤៩ ០០៣,៩ លានរៀល ។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ..........................................២៦០ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ១៦ ៧៦៨,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន........................២៤៣ ២៣១,៨ លានរៀល ។

## មាត្រា ៤.-

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ:

- ច្បាប់ហិរញ្ញវត្ថុ..........................................១០ ១៣៥ ៦២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន..............................  ៩ ៨២៧ ៤៥២,១ លានរៀល

ដូច្នេះ ចំណាយអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...៣០៨ ១៧៤,៩ លានរៀល ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ :

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.......................................... ៨ ២៦៨ ៧០៣,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ៨ ២០៤ ៤៤១,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ៦៤ ២៦១,៣ លានរៀល ។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៨៦៦ ៩២៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ១ ៦២៣ ០១០,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២៤៣ ៩១៣,៦ លានរៀល ។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៥៣៦ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ១ ៣១១ ២៣១,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២២៤ ៧៦៨,៥ លានរៀល។

ខ. ចំណាយមូលធន សម្រាប់ការរំលស់បំណុល

- ច្បាប់ហិរញ្ញវត្ថុ..........................................៣៣០ ៩២៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ៣១១ ៧៧៨,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ១៩ ១៤៥,១ លានរៀល ។

**មាត្រា ៥.-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិកាដាក់ស្តែងឆ្លងកាត់តេនាគារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ :

- ចំណូលថវិកាអនុវត្តដាក់ស្តែងបានចំនួន.......... ១១ ០៣០ ៤៦០,៩ លានរៀល
- ចំណាយថវិកាអនុវត្តដាក់ស្តែងបានចំនួន........ ៩ ៨២៧ ៤៥២,១ លានរៀល
- អតិរេកនៃថវិកាមានចំនួន..................... (+) ១ ២០៣ ០០៨,៨ លានរៀល ។

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៅក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ អតិរេកនៃថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ មានចំនួនទឹកប្រាក់ (+)១ ២០៣ ០០៨,៨ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលដែលបានបើកនៅក្នុងលេខានៃរតនាគារជាតិ ។

## ផ្នែកទី ៣

## បទប្បញ្ញត្តិស្តីពី

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

**មាត្រា ៦.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងយោងមាត្រា ១៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ត្រូវបានអនុម័តយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដូចខាងក្រោម :

- ឥណទានថវិកាបន្ថែមសម្រាប់ទូទាត់ជម្រះបុរេប្រទានចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១៤ ចំនួន.......................................................... ២៧៦ ៥០០,០ លានរៀល
- អនុវត្តដាក់ស្តែងបានចំនួន...................................២៦៦ ៥៣៦,៣ លានរៀល

## ផ្នែកទី ៤

## កិច្ចប្រតិបត្តិការចំណូល-ចំណាយអនុវត្តមិនឆ្លងកាត់រតនាគារជាតិ

**មាត្រា ៧.-**

ការអនុវត្តចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ សម្រេចបានលទ្ធផលដូចតទៅ :

- ច្បាប់ហិរញ្ញវត្ថុ......................................៣ ៤៦០ ០០០,០ លានរៀល
- អនុវត្តដាក់ស្តែងបានចំនួន.......................... ៤ ២៤០ ៤៧៩,៩ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន...................... ៧៨០ ៤៧៩,៩ លានរៀល ។

ROYAUME DU CAMBODGE ◆ LE MINISTRE DU PALAIS ROYAL ◆ ក្រសួងព្រះបរមរាជវាំង

# ផ្នែកទី ៥
# តុល្យភាពហិរញ្ញវត្ថុសាធារណៈ

## មាត្រា ៨.-

តុល្យភាពហិរញ្ញវត្ថុដែលបានសម្រេចជាស្ថាពរ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ជាតិ ដូចខាងក្រោម :

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | ហិរញ្ញប្បទាន |
|---|---|---|
| I- ចំណូលក្នុងប្រទេស | ១១ ០១៣ ៦៩២,៧ | |
| I.១. ចំណូលចរន្ត | ១០ ៨២៩ ៦៩៦,៦ | |
| I.២. ចំណូលមូលធនក្នុងប្រទេស | ១៨៣ ៩៩៦,១ | |
| II- ចំណាយថវិកា | ១៣ ៧៥៦ ១៥៣,១ | |
| II.១. ចំណាយចរន្ត | ៨ ២០៤ ៤៤១,៧ | |
| II.២. ចំណាយមូលធន | ៥ ៥៥១ ៧១១,៤ | |
| (មិនគិតការរំលស់បំណុលបរទេស៣១១ ៧៧៨,៩ លានរៀលទេ) | | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៣១១ ២៣១,៥ | |
| - ដោយថវិការដ្ឋ | ១ ២២៣ ៨៦០,២ | |
| • គម្រោងវិនិយោគ | ៩៣០ ៨៤៩,៤ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ២៩៣ ០១០,៧ | |
| - ដោយមូលនិធិទ្រទ្រង់ថវិកា | ៨៧ ៣៧១,៣ | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៤០ ៤៧៩,៩ | |
| ក. អតិរេកនៃថវិកាចរន្ត (I.១-II.១) | (+)២ ៦២៥ ២៥៤,៩ | |
| ខ. ឱនភាពនៃថវិកាទូទៅ (I-II) | (-)២ ៧៤២ ៤៦០,៤ | |
| III- ហិរញ្ញប្បទាននៃឱនភាព | | (+)២ ៧៤២ ៤៦០,៤ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | (+)៣ ៩៤៥ ៤៦៩,២ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | (+)១៦ ៧៦៨,២ |
| • វិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)៤ ២៤០ ៤៧៩,៩ |
| • ការទូទាត់ការខ្ចី | | (-)៣១១ ៧៧៨,៩ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (-)១ ២០៣ ០០៨,៨ |
| • បញ្ញើរាជរដ្ឋាភិបាល | | (-)១ ២៧៣ ៦១១,៩ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | (+)៧០ ៦០៣,១ |

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

# ជំពូកទី ២
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ

## មាត្រា ៦.-

ត្រូវបានយល់ព្រមលើការអនុវត្តជំពូកទី ៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។ ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោម :

### ក. កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា រដ្ឋបាលរាជធានី ខេត្ត ឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស (+) /ខ្វះ (-) |
| សរុបចំណូលថវិកា | ៦៥៦ ៤៩០,០៥ | ៨១១ ៦៥៩,១៥ | ១២៣,៦% | + ១៥៥ ១៦៩,១០ |
| សរុបចំណាយថវិកា | ៦៥៦ ៤៩០,០៥ | ៧១៦ ៩០៣,០៨ | ១០៩,២% | + ៦០ ៤១៣,០៣ |
| អតិរេកនៃថវិកាចំណូលនិងចំណាយ | | +៩៤ ៧៥៦,០៧ | | |
| កិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលរាជធានី ខេត្ត | | | | |
| I. ចំណូលថវិកា | ៦៥៦ ៤៩០,០៥ | ៨១១ ៦៥៩,១៥ | ១២៣,៦% | + ១៥៥ ១៦៩,១០ |
| - ចំណូលចរន្ត | ៥៧០ ៥៦៨,០០ | ៦២៦ ៣២៨,១០ | ១០៩,៨% | + ៥៥ ៧៦០,១០ |
| • ចំណូលសារពើពន្ធ | ៥៤៣ ៨៦០,០០ | ៥៩៣ ០១៥,០៨ | ១០៩,០% | + ៤៩ ១៥៥,០៨ |
| • ចំណូលមិនមែនសារពើពន្ធ | ២៦ ៧០៨,០០ | ៣៣ ៣១៣,០២ | ១២៤,៧% | + ៦ ៦០៥,០២ |
| - ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៨៥ ៩២២,០៥ | ១៨៥ ៣៣១,០៥ | ២១៥,៧% | + ៩៩ ៤០៩,០០ |
| II. ចំណាយថវិកា | ៦៥៦ ៤៩០,០៥ | ៧១៦ ៩០៣,០៨ | ១០៩,២% | + ៦០ ៤១៣,០៣ |
| - ចំណាយចរន្ត | ៥២០ ៣៩៧,០០ | ៥៨៣ ០៨៩,៤៣ | ១១២,០% | + ៦២ ៦៩២,៤៣ |
| - ចំណាយមូលធន | ១២០ ៤៤១,០០ | ១១៨ ១៦១,៦០ | ៩៨,១% | -២ ២៧៩,៤០ |
| - ចំណាយសង្កាត់ចំណុះរាជធានី | ១៥ ៦៥២,០៥ | ១៥ ៦៥២,០៥ | ១០០,០% | ០,០០ |

### ខ. កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៤ | ឆ្នាំ២០១៤ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស (+) /ខ្វះ (-) |
| សរុបចំណូលថវិកា | ៨៧ ៨០៣,៤៤ | ៨៩ ៧១១,៧៣ | ១០២,២% | + ១៩០៨,២៩ |
| សរុបចំណាយថវិកា | ៨៧ ៨០៣,៤៤ | ៨៥ ២៨៥,៧៣ | ៩៧,១% | -២ ៥១៧,៧១ |
| អតិរេកនៃថវិកាចំណូលនិងចំណាយ | | +៤ ៤២៦,០០ | | |

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

| | | | | |
|---|---|---|---|---|
| កិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលក្រុង ស្រុក | | | | |
| I. ចំណូលថវិកា | ៨៧ ៨០៣,៤៤ | ៨៩ ៧១១,៧៣ | ១០២,២% | + ១ ៩០៨,២៩ |
| - ចំណូលចរន្ត | ១ ២៥៤,២៨ | ៣ ៧២៣,៩៩ | ២៩៦,៩% | + ២ ៤៦៩,៧១ |
| • ចំណូលមិនមែនសារពើពន្ធ | ១ ២៥៤,២៨ | ៣ ៧២៣,៩៩ | ២៩៦,៩% | + ២ ៤៦៩,៧១ |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៨៦ ៥៤៩,១៦ | ៨៥ ៩៨៧,៧៤ | ៩៩,៤% | -៥៦១,៤២ |
| II. ចំណាយថវិកា | ៨៧ ៨០៣,៤៤ | ៨៥ ២៨៥,៧៣ | ៩៧,១% | -២ ៥១៧,៧១ |
| - ចំណាយចរន្ត | ៦៩ ០៤៤,២៨ | ៦៦ ៥២៦,៦៥ | ៩៦,៤% | -២ ៥១៧,៦៣ |
| - ចំណាយសង្កាត់ចំណុះក្រុង | ១៨ ៧៥៩,១៦ | ១៨ ៧៥៩,០៨ | ១០០,០% | -០,០៨ |

**មាត្រា ១០.-**

អនុលោមតាមមាត្រា ៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០១១ អតិរេកនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានទឹកប្រាក់ចំនួន ៩៩ ១៨២,០៧ លាន រៀល ត្រូវកត់ត្រាចូលគណនីលទ្ធផលនៃរតនាគារជាតិ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញ្ញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពស. ១៦០២. ០៥០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខ: ១៦៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**



**សយ សុខា**